# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិ<br>ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា<br>សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី

រាជធានីភ្នំពេញថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥

ខ្ញុំហៀបនឹងបញ្ចប់ដំណើរបេសកកម្មលើកទី១២ ដែលជាបេសកកម្មចុងក្រោយរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ វាគឺបុព្វសិទ្ធិដែលខ្ញុំបានបំរើប្រជាជនកម្ពុជាក្នុងរយៈពេលប្រាំមួយឆ្នាំនេះ។

ជាបឋម ខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ឲ្យខ្ញុំនូវកិច្ចសហប្រតិបត្តិការប្រកប ដោយវិជ្ជមាននិងក្នុងន័យស្ថាបនានៅក្នុងអំឡុងពេលនៃបេសកកម្មនេះ។ ដោយសារតែខ្ញុំមិនអាចជួបជាមួយលោកនាយករដ្ឋមន្ត្រីអំឡុងបេសកម្មនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចសន្ទនាដែលខ្ញុំមានជាមួយគូសន្ទនាក្នុងជួររដ្ឋាភិបាល ដែលបានផ្តល់ព័ត៌មានដោយភាពស្មោះត្រង់ និងគ្មានការលាក់លៀម។

អំឡុងបេសកកម្មលើកនេះ ខ្ញុំបានជួបជាមួយ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម ម៉ក់ សម្បត្តិ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ នៅវិមានរដ្ឋសភា ខ្ញុំបានជួបផងដែរជាមួយមេដឹកនាំគណបក្សភាគតិច រាប់ទាំងលោក សម រង្ស៊ី និងលោក កឹម សុខា ។ ដូចដំណើរបេសកកម្មលើកមុនៗរបស់ខ្ញុំដូច្នោះដែរ ខ្ញុំបានជួបពិភាក្សាជាមួយភាគីពាក់ព័ន្ធជាច្រើន រួមមាន ពលរដ្ឋសាមញ្ញ ក្រុមយុវជន សហជីពកម្មករ អង្គការជនពិការ និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ក៏ដូចជាជួបជាមួយប្រធានគណៈមេធាវី ប្រធាន និងសមាជិកសភាពាណិជ្ជកម្មកម្ពុជា និងសមាជិកសហគមន៍អន្តរជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ ខ្ញុំបានធ្វើទស្សនកិច្ចនៅកាន់តំបន់បឹងកក់ និងបុរីកីឡា និងបានទទួលញ្ញតិជាលក្ខណៈបុគ្គល និងជាក្រុមផងដែរ ដែលពួកគេ

មកពីតំបន់ឆ្ងាយៗតាំងពីខេត្តព្រះវិហារ បានយកករណីដីធ្លីរបស់ពួកគេឲ្យខ្ញុំជួយរកដំណោះស្រាយ។ រាល់ការជួបប្រជុំរបស់ខ្ញុំ ខ្ញុំបានទទួលការគោរពស្វាគមន៍ និងការអរគុណ សម្រាប់ការងារដែលបានធ្វើសម្រាប់ប្រជាជនកម្ពុជា។

ខ្ញុំត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅខែមិនា ឆ្នាំ ២០០៩ ហើយគិតមកត្រឹមខែមេសាឆ្នាំនេះ ខ្ញុំមានបុព្វសិទ្ធិបម្រើការជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាអស់រយៈពេលអតិបរមាប្រាំមួយឆ្នាំ។ ក្នុងរយៈពេលនេះ ខ្ញុំបានដាក់ជូនរបាយការណ៍ធំៗចំនួនប្រាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ហើយដែលរបាយការណ៍នីមួយៗមានការវិភាគលំអិតអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងដំណាក់កាលនីមួយៗ និងមានវិធីសាស្ត្រធ្វើការងារច្រើនបែប ដោយផ្តោតជាពិសេសលើ កំណែទម្រង់តុលាការ សភា ការបោះឆ្នោត និងដីធ្លី ។ របាយការណ៍នីមួយៗរបស់ខ្ញុំ បានភ្ជាប់ជាមួយនូវបញ្ជីអនុសាសន៍ ដែលតាក់តែងឡើងដើម្បីជួយដល់រដ្ឋាភិបាលក្នុងការអនុវត្តរបៀបវារៈកំណែទម្រង់ និងដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ខ្ញុំរីករាយសូមបញ្ជាក់ថា អនុសាសន៍របស់ខ្ញុំភាគច្រើន ត្រូវបានអនុវត្ត ហើយអនុសាសន៍ខ្លះទៀតកំពុងស្ថិតក្នុងដំណើរការអនុវត្ត។

របាយការណ៍ចុងក្រោយបំផុត និងចុងបញ្ចប់របស់ខ្ញុំ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺបានដាក់នៅក្នុងខែកញ្ញា ឆ្នាំ២០១៤ ដែលផ្តោតលើឯករាជ្យភាពរបស់ស្ថាប័នរដ្ឋ រួមទាំងលទ្ធភាពនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យស្របតាមគោលការណ៍ទីក្រុងប៉ារីស។ ក្នុងការជួបពិភាក្សារបស់ខ្ញុំក្នុងសប្តាហ៍នេះ ដៃគូសន្ទនាមួយចំនួនបានស្នើឲ្យខ្ញុំផ្តល់អនុសាសន៍គន្លឹះៗមួយចំនួន ដោយសារអាណត្តិរបស់ខ្ញុំបានដល់ទីបញ្ចប់ហើយ។ ប្រសិនបើខ្ញុំត្រូវជ្រើសរើសយកអនុសាសន៍មួយ ជាអនុសាសន៍រួមនៃអនុសាសន៍ទាំងអស់នោះ គឺ រដ្ឋាភិបាលគួរពិចារណាអំពីភាពមិនពេញចិត្តជាទូទៅនៃស្ថាប័នឯករាជ្យ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានការសោកស្តាយ ដោយកត់សម្គាល់ថា ស្ថាប័នរដ្ឋភាគច្រើនដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ជាអកុសល នៅតែខ្វះគណនេយ្យភាព និង តម្លាភាព ដែលចាំបាច់អាចឲ្យប្រជាពលរដ្ឋមានការជឿជាក់និងការជឿទុកចិត្តបាន។ កំណែទម្រង់មិនបានធ្វើលើវិស័យទាំងនេះ ក្នុងសន្ទុះមួយលឿនគ្រប់គ្រាន់នោះទេ បើទោះបីជាខ្ញុំទទួលស្គាល់ពីការរីកចំរើនគួរឱ្យកត់សម្គាល់នៅក្នុងវិស័យមួយចំនួនក្តី។ គោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យសេរី ផ្អែកលើលទ្ធិនៃការបែងចែកអំណាច និងគោលការណ៍ពិនិត្យតុល្យភាពអំណាច

អាចនិយាយម្យ៉ាងទៀតថា ស្ថាប័ននៃអង្គនីតិប្រតិបត្តិដែលទទួលខុសត្រូវអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល និងការពារសិទ្ធិមនុស្ស ត្រូវតែបានដាក់ឲ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ដោយស្ថាប័នមួយឯករាជ្យ មានតួនាទីឃ្លាំមើលការអនុវត្តរបស់ស្ថាប័នទាំងនោះ។ នេះគឺជាដំណាក់កាលមួយដ៏សំខាន់បំផុត ដែលខ្ញុំជឿជាក់ថា កម្ពុជា បច្ចុប្បន្ននេះ ត្រូវឈរលើគោលការណ៍នេះ។

ខ្ញុំចាប់អារម្មណ៍ជាពិសេសថា បេសកកម្មរបស់ខ្ញុំកើតមាន ក្រោយព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់នៅទីក្រុងប៉ារីស។ គ្មាននរណាម្នាក់ (ក្រៅពីរូបខ្ញុំទេ) ដែលបានអះអាងពីសេចក្តីការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។ ទោះ ជាយ៉ាងណាក៏ដោយ ខ្ញុំសូមបញ្ជាក់ថា ដើម្បីធ្វើកិច្ចការនោះបាន យើងត្រូវតែប្រុងប្រយ័ត្នអំពីមេរៀនថ្ងៃទី៩ ខែវិច្ឆិកា។ ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម តាមរយៈការមិនគិតគូរច្បាស់លាស់អំពីសិទ្ធិមនុស្ស វាគ្រាន់តែជាការចាក់ប្រេងដុតឲ្យមានការចងកំហឹង និងភាពជ្រុលនិយម។ មានតែស្ថាប័នជាតិឯករាជ្យ ដែលមានតួនាទីពិនិត្យលើការអនុវត្តទេ ដែលអាចធានាបានល្អបំផុត ប្រឆាំងនឹងការអាចមានការរំលោភអំណាច ក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ។

ដោយសារតែហេតុនេះហើយ ទើបនៅដើមអាណត្តិរបស់ខ្ញុំ ខ្ញុំបានសម្រេចផ្តោតជាសំខាន់លើស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិមនុស្ស។ មន្ត្រីរដ្ឋាភិបាល និងអ្នកដទៃទៀតតែងតែសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំផ្តល់អនុសាសន៍ឲ្យធ្វើកំណែទម្រង់ស្ថាប័នដែលមិនមានបញ្ហាអ្វីផងនោះ។ គេប្រាប់ខ្ញុំថា ស្ថាប័នទាំងនោះ មិនមានអ្វីជាបញ្ហាទេ ឧទាហរណ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ឥឡូវនេះ បញ្ហាត្រូវបានលាតត្រដាងហើយ ភាពខ្សោយក៏ត្រូវបានបង្ហាញផងដែរ។ បច្ចុប្បន្ននេះ ការអំពាវនាវឲ្យមានគណនេយ្យភាពកាន់តែមានសំលេងឮខ្លាំងជាងមុន ហើយខ្ញុំជឿជាក់ថា សំលេងនេះនឹងនៅតែឮមិនបាត់ទេ។ ដំណើរការក្តីនៅតែបន្តធ្វើនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នេះគឺជាករណីជាក់ស្តែង។ គេត្រូវចំណាយពេលម្ភៃឆ្នាំហើយ ចាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីឲ្យគណនេយ្យភាពក្លាយជាបញ្ហាអាទិភាពមួយក្នុងប្រទេសកម្ពុជា។ ភាពបន្ទាន់នៅពេលនោះ គឺការបង្កើត និងការពង្រឹងសន្តិភាពខ្លួនវាផ្ទាល់។ ការរីកចម្រើនជាធម្មតារបស់ប្រទេសមួយដែលសម្រេចបានសន្តិភាព និងស្ថិរភាព ជួបប្រទះការទាមទារកាន់តែច្រើនឡើង ឲ្យមានអភិបាលកិច្ច និងយុត្តិធម៌ កាន់តែប្រសើរឡើងថែមទៀត សម្រាប់មនុស្សគ្រប់គ្នា អាចបោះជំហានប្រកបដោយអត្ថន័យឆ្ពោះទៅកាន់គោលដៅនោះ។ ខ្ញុំមានការជឿជាក់ថា នៅទីបំផុត

កម្ពុជានឹងធ្វើដំណើរលើផ្លូវនេះ ហើយខ្ញុំជឿថា ខ្ញុំបានរួមចំណែកត្រួសត្រាយផ្លូវសម្រាប់គោលដៅនោះ។

**សភា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ខ្ញុំមានសេចក្តីរីករាយចំពោះការវិវត្តន៍ចម្បងៗផ្នែកនយោបាយ ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំបានអំពាវនាវដដែលៗ ទាំងជាសាធារណៈក្តី និងជាឯកជនក្តី ឲ្យមានការបង្កើតបរិយាកាសនយោបាយមួយ ដែលអាចផ្តល់លទ្ធភាពដល់មេដឹកនាំគណបក្សប្រឆាំង ដើម្បីវិលត្រឡប់ចូលប្រទេសវិញពីការនិរទេសរបស់គាត់នៅទីក្រុងប៉ារីស ហើយ **ឯកឧត្តម សម រង្ស៊ី** ក៏បានទទួលការលើកលែងទោសពីព្រះមហាក្សត្រ ដើម្បីឲ្យគាត់វិលត្រឡប់មកវិញនៅចំពេលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ។ ដោយមានជម្លោះផ្សេងៗជុំវិញលទ្ធផលនៃការបោះឆ្នោត ប្រទេសនេះ បានឆ្លងកាត់អស្ថេរភាពនយោបាយអស់មួយឆ្នាំទៀត។

ខ្ញុំមានសេចក្តីរីករាយ និងមានអារម្មណ៍ធូរស្រាលនៅពេលដែលគណបក្សទាំងពីរ បានព្រមព្រៀងគ្នាលើដំណោះស្រាយនយោបាយមួយកាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ដើម្បីត្រួសត្រាយផ្លូវឲ្យគណបក្សប្រឆាំងចូលរួមក្នុងសភា។ ខ្ញុំមានសេចក្តីសោមនស្សរីករាយថា អនុសាសន៍ផ្សេងៗរបស់ខ្ញុំស្តីពីកំណែទម្រង់បោះឆ្នោត ឥឡូវនេះ ហាក់បីដូចជា ពិតជាបានក្លាយជាផ្នែកមួយនៃរបៀបវារៈជាតិ ដែលជាផ្នែកមួយគួរឲ្យកត់សំគាល់បំផុត មានដូចជា ការផ្តល់ឋានៈជាស្ថាប័នដល់គណៈកម្មាធិការរៀបចំការបោះឆ្នោត។ ជាជំហ៊ានបន្ទាប់ ខ្ញុំសូមលើកទឹកចិត្តដល់ គណបក្សទាំងពីរឲ្យធ្វើការរួមគ្នាក្នុងការដោះស្រាយការខ្វែងគំនិតគ្នាចម្បងៗ ដើម្បីឲ្យការបោះឆ្នោតលើកក្រោយៗ កុំឲ្យបង្កើតមានជាជម្លោះស្រដៀងគ្នាផ្សេងៗ ដែលបានអូរបន្លាយពីការបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ ២០១៣។ ខណៈពេលដែលរដ្ឋាភិបាល និងគណបក្សកាន់អំណាច មានការទទួលខុសត្រូវកាន់តែធំ ដើម្បីធានាថា កំណែទម្រង់នយោបាយ តុលាការ និងសង្គម ដែលបានសន្យា ត្រូវបានធ្វើឡើងនោះ គណបក្សសម្លេងភាគតិច ក៏ត្រូវមានការទទួលខុសត្រូវរបស់ខ្លួនដូចគ្នាយ៉ាងខ្លាំងដែរ ហើយត្រូវធានាថា តួនាទីដែលខ្លួនត្រូវបំពេញ គឺជាតួនាទីជាគោលការណ៍មួយ ហើយមិនត្រូវបាននាំមុខដោយការទទួលបានការចំណេញសំរាប់រយៈពេលខ្លីនោះឡើយ។

កង្វល់មួយក្នុងចំណោមកង្វល់ទាំងឡាយដែលខ្ញុំមានចំពោះប្រទេសនេះ គឺការអាចកើតមានឡើងនៃភាពតានតឹងខាងពូជសាសន៍រវាងក្រុមជាតិពន្ធទាំងឡាយ ហើយ ហេតុដូច្នេះ ខ្ញុំសូមអំពាវនាវដល់គ្រប់ភាគី ត្រូវខិតខំធ្វើការចូលរួមចំណែករបស់ខ្លួនយ៉ាងខ្លាំងបំផុតដើម្បីកសាង សង្គមមួយ

ប្រកបដោយការអត់អោន មានការចូលរួម និងសុខដុមរម្យនា។ ក្រោយពីការធ្វើដំណើរដ៏វែងឆ្ងាយ ឆ្ពោះមកកាន់អភិបាលកិច្ចល្អ ប្រជាធិបតេយ្យកាន់តែរឹងមាំ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សកាន់តែខ្លាំងឡើង គេមិនគួរឲ្យមានលំហរនៅក្នុងនយោបាយកម្ពុជាសំរាប់ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងការរើសអើងណាមួយដោយផ្អែកលើពូជសាសន៍ យេនឌ័រ ដើមកំណើត ភេទ ឬជំនឿឡើយ។

ខ្ញុំជឿជាក់ថា សភាថ្មីដែលមានពីរគណបក្សនេះ យល់ថា ប្រជាពលរដ្ឋសង្ឃឹមថា ខ្លួននឹងបំពេញញមុខងារកាន់តែមានតម្លាភាព។ តាមសេចក្តីរាយការណ៍ មានសេចក្តីព្រាងច្បាប់មួយចំនួនកំពុងត្រូវបានរៀបចំ ដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់ការបញ្ចេញមតិ និងការចូលរួមតាមបែបលទ្ធិប្រជាធិតេយ្យ រាប់បញ្ចូលទាំងសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល សហជីព និងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីធឺណែត។ ជាថ្មីម្តងទៀត ខ្ញុំ សូមជម្រុញដល់សភា មេត្តាធានាឲ្យមានការបើកចំហរ និងតម្លាភាពនៅក្នុងដំណើរតាក់តែងច្បាប់ទាំងនេះ។

## ប្រព័ន្ធយុត្តិធម៌

ខ្ញុំជឿថាប្រព័ន្ធយុត្តិធម៌គឺជាស្ថាប័នគន្លឹះ ដើម្បីធានាកិច្ចការពារសិទ្ធិមនុស្ស។ ខ្ញុំបានឧទ្ទិសរបាយការណ៍អំពីវិស័យនេះ គ្រាដំបូងឆ្នាំ ២០១០ របស់ខ្ញុំដោយ ផ្តោតទៅលើការពង្រឹងឯករាជ្យភាព និងការកសាងសមត្ថភាពប្រព័ន្ធយុត្តិធម៌។ ការអនុម័តច្បាប់សំខាន់ ៣ នៃប្រព័ន្ធយុត្តិធម៌ គឺច្បាប់ស្តីពីការចាត់តាំងតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កើតចេញពីអនុសាសន៍ចម្បងរបស់ខ្ញុំ អំពីកំណែទម្រង់វិស័យតុលាការ។ ទន្ទឹមពេលដែលមានការខ្វះចន្លោះខ្លះៗ ទាំងផ្នែកដំណើរការ និងខ្លឹមសារនៃច្បាប់ទាំង ៣ ខ្ញុំនៅតែមានសុទិដ្ឋិនិយមថា ប្រព័ន្ធតុលាការកម្ពុជានឹងអាចប្រតិបត្តិទៅតាមក្របខ័ណ្ឌគតិយុត្តិ ដែលច្បាស់លាស់ជាបណ្តើរៗ។

រហូតមកដល់ពេលនេះតុលាការកម្ពុជាមិនទាន់បានផ្តល់យុត្តិធម៌ តាមវិធីដែលប្រជាជនកម្ពុជាទាមទារឡើយ។ មានករណីរំលោភសិទ្ធិមនុស្សយ៉ាងច្រើនដែលមិនទាន់ចាប់ជនទទួលខុសត្រូវអោយមកទទួលទោសនៅឡើយ។ ខ្ញុំគ្រាន់តែលើកឡើងចំពោះករណីនៃព្រឹត្តិការណ៍ថ្ងៃទី ២ និងថ្ងៃទី ៣ ខែមករាកាលពីឆ្នាំមុន ដែលកាលនោះគឺមានមនុស្ស ៥ នាក់ត្រូវបានសំលាប់ ហើយមនុស្សម្នាក់ បាត់ខ្លួន និងជាច្រើននាក់ទៀតរងរបួស ។

កាលពីម្សិលមិញគឺជាខួបនៃការបាញ់សម្លាប់មេដឹកនាំសហជីពកម្មករដ៏ល្បីល្បាញគឺលោក ជា វិជ្ជា។ ១១ ឆ្នាំកន្លងមកហើយ គ្មានការស៊ើបអង្កេតដោយហ្មត់ចត់ ហើយក៏មិនមានបុគ្គលដែលទទួលខុសត្រូវក្នុងអំពើឃាតកម្មនេះ ត្រូវបានចាប់ខ្លួនឡើយ។ បុរស ២ នាក់ដែលត្រូវបានកាត់ទោស ក្រោយមកត្រូវបានរក ឃើញថាមិនជាប់ពាក់ព័ន្ធ ហើយបន្ទាប់មកក៏ត្រូវបានដោះលែងក្នុងឆ្នាំ ២០១៣ បន្ទាប់ពីបានជាប់ ពន្ធនាគារអស់រយៈពេលជាច្រើនឆ្នាំរួចមក។

មានការយល់ឃើញជាទូទៅថាអ្នកមានធនធាន និងអ្នកមានអំណាចនៅតែគេចផុតពីសំណាញ់ច្បាប់។ ខ្ញុំត្រូវបានគេប្រាប់រហូតមកដល់ថ្ងៃនេះថា លោក ឈូក បណ្ឌិត អតីតអភិបាលក្រុងបាវិតនៅតែមានសេរីភាពរស់នៅក្រៅពន្ធនាគារនៅឡើយ មិនដែលជាប់គុកសូម្បីតែ ១ ថ្ងៃ ទោះបីជាមានការកាត់ទោស និងផ្តន្ទាទោសពីបទបាញ់កម្មការនីចំនួន ៣ នាក់កាលពីឆ្នាំ ២០១២ ក៏ដោយ។

ទាំងនេះគ្រាន់តែជាការលើកឡើងនូវករណីខ្លះៗ ដើម្បីសបញ្ជាក់ថាហេតុអ្វីពាក្យនិទណ្ឌភាពនៅតែបន្តប្រើពេលណាគេជជែកអំពីវិស័យយុត្តិធម៌នៅកម្ពុជា។ វប្បធម៌និទ្ទណ្ឌភាពនៅក្នុងប្រទេសនេះ គឺនៅតែជាបញ្ហាកង្វល់សំរាប់រូបខ្ញុំ ដែលខ្ញុំតែងតែលើកឡើងជដែលៗជាមួយរដ្ឋាភិបាល។ ខ្ញុំត្រូវបានគេធានាសាជាថ្មីទៀតក្នុងដំណើរទស្សនកិច្ចនេះថា ឧបទ្ទវហេតុហិង្សាកាលពីខែមករាឆ្នាំ ២០១៤ ត្រូវបានស៊ើបអង្កេត ហើយត្រូវបានបញ្ជូនទៅតុលាការ។ តាមពិតខ្ញុំសូមស្វាគមន៍ចំពោះការវិវត្តនេះ ប៉ុន្តែខ្ញុំសង្ឃឹមថាខ្ញុំនឹងមិនបញ្ចប់អាណត្តិការងាររបស់ខ្ញុំក្នុងខែមេសាខាងមុខនេះ ដោយមិនបានឃើញបុគ្គលដែលទទួលខុសត្រូវ ត្រូវបាននាំខ្លួនយកមកកាត់ទោសនោះទេ។

ខ្ញុំមានកង្វល់ដោយឃើញតុលាការ នៅតែត្រូវបានបន្តប្រើប្រាស់ ដើម្បីគំរាមកំហែងក្រុមដែលមានមតិរិះគន់រដ្ឋាភិបាល ដូចជាអ្នកការពារសិទ្ធិមនុស្ស សកម្មជនដីធ្លី អ្នកសារព័ត៌មាន អ្នកដឹកនាំសហជីពកម្មករ និងសមាជិកបក្សប្រឆាំង។ ការគំរាមកំហែង ឬការចោទប្រកាន់ និងការកាត់ទោសឲ្យជាប់ពន្ធនាគារជាក់ស្តែង ជួនកាលធ្វើក្នុងរូបភាពវិធានការប្រឆាំងអំពើភេរវកម្ម ឬអំពើកុបកម្ម តែអាចត្រូវបានគេពិពណ៌នាថាជាការធ្វើទុក្ខបុកម្នេញពីប្រព័ន្ធតុលាការទៅវិញទេ។ ជាឧទាហរណ៍៖

សមាជិកសភាជាប់ឆ្នោតជាច្រើននៃបក្សប្រឆាំង ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១៤។ ពួកគេត្រូវបានចាប់ខ្លួនភ្លាមៗពីបទញុះញង់ និងអំពើកុបកម្ម។ ផ្ទុយទៅវិញគ្មានការស៊ើបអង្កេតត្រូវបានធ្វើឡើង ដើម្បីស្វែងរកកងកម្លាំងសុន្តិសុខ ដែលត្រូវបានគេមើលឃើញថាបាន

វាយដំទៅបាតុករ។ ក្រោយមកសមាជិកសភាជាប់ឆ្នោតទាំងនោះ ត្រូវបានដោះលែងដោយសារមានកិច្ចព្រមព្រៀងនយោបាយ ដែលនាំឲ្យមានការជឿថាព្រឹត្តិការណ៍ទាំងពីរនេះមានភាពពាក់ព័ន្ធគ្នា។

សម្មជនដីធ្លីត្រូវបានគេប្ដឹងទៅតុលាការនៅទូរទាំងប្រទេស។ កាលពីថ្ងៃទី ១០ ខែវិច្ឆិកាឆ្នាំ ២០១៤ ស្ត្រី ៧ នាក់មកពីសហគមបឹងកក់ ត្រូវបានចាប់ខ្លួនដោយសារការធ្វើបាតុកម្មនៅមុខសាលារាជធានីភ្នំពេញ។ ផ្ទះសម្បែងរបស់ពួកគាត់ត្រូវទឹកជន់លិច ហើយនៅពេលពួកគាត់ទាមទារតវ៉ា ត្រូវបានគេចាប់ខ្លួន និងកាត់ទោសភ្លាមៗក្នុងរយៈពេលមួយថ្ងៃ។ ម្សិលមិញនេះខ្ញុំបានទៅចូលរួមសវនាការនៅសាលាឧទ្ធរណ៍ ដើម្បីឃ្លាំមើលសវនាការលើករណីរបស់ស្ត្រីទាំង ៧ នាក់នេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាស្ត្រីទាំងនេះ និងសហចុងចោទឯទៀតក្នុងសំណុំរឿងនេះទទួលបាននូវការប្រព្រឹត្តយ៉ាងត្រឹមត្រូវក្នុងប្រព័ន្ធយុត្តិធម៌។ ករណីទាំងនេះគឺជារោគសញ្ញា បញ្ជាក់ពីរបៀប ដែលតុលាការត្រូវបានប្រើប្រាស់ក្នុងរឿងនយោបាយ។ តុលាការក៏ត្រូវបានគេកំពុងប្រើប្រាស់ ដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកមានធនធាន និងអ្នកមានអំណាច។ ឧទាហរណ៍៖

លោក លី ស្រ៊ាខេង និងក្រុមគ្រួសាររបស់គាត់ ទទួលរងការគំរាមកំហែងជាច្រើនឆ្នាំ រងការវាយដំ និងការដាក់ពន្ធនាគារ រួមទាំងមានការបោះពស់វែកមានពឹសចូលក្នុងផ្ទះរបស់គាត់ ក្នុងការប៉ុនប៉ងបង្ខំគ្រួសារនេះឲ្យចេញពីដីធ្លីរបស់ខ្លួន។ ទោះបីជាមានបណ្ដឹងជាច្រើនបានដាក់ប្ដឹងចូលតុលាការពីសំណាក់គ្រួសារនេះក៏ដោយ ក៏មិនមានចំណាត់ការផ្លូវច្បាប់ទៅលើជនបង្កត្រូវបានធ្វើឡើងនោះទេ។ ផ្ទុយទៅវិញ លោក លី ស្រ៊ាខេង និងសមាជិកគ្រួសាររបស់គាត់ត្រូវបានចាប់ខ្លួនបន្ទាប់ពីមានបណ្ដឹងពីក្រុមហ៊ុនដាក់សម្ពាធលើគ្រួសារគាត់ឲ្យលក់ដី។ កូនស្រីរបស់គាត់អាយុ ២៣ ឆ្នាំ បន្តជាប់ពន្ធនាគាររហូតដល់ថ្ងៃនេះ។

ការចាប់ខ្លួន ឬការឃុំខ្លួនដែលជាការដាក់ទណ្ឌកម្ម ចំពោះការអនុវត្តសិទ្ធិស្របច្បាប់ ធានាការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ រួមមានសេរីភាពក្នុងការប្រមូលផ្ដុំ បង្កើត ឬចូលរួមសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ដូចជាសិទ្ធិក្នុងការចូលរួមក្នុងជីវភាពនយោបាយ គឺជាការប្រព្រឹត្តតាមទំនើងចិត្ត។ ខ្ញុំសូមបញ្ជាក់ហើយបញ្ជាក់ទៀតថា នីតិរដ្ឋត្រូវផ្សារភ្ជាប់ជាមួយការទទួលខុសត្រូវ។ នីតិរដ្ឋនេះទាមទារឲ្យតុលាការផ្ដល់នូវយុត្តិធម៌ ប្រកបដោយភាពឯករាជ្យ និងមិនទទួលយកឥទ្ធិពលពីខាងក្រៅ។ វាជាអំពើនាំមកនូវផលអាក្រក់ដល់ស្ថាប័នតុលាការកម្ពុជា ប្រសិនណាបើយើងយកចិត្តទុកដាក់ត្រឹមតែការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពតុលាការ នៅពេលដែលកិត្តិយសរបស់ស្ថាប័

ននេះ ទទួលរងនូវការខូចខាតដោយសារកើតចេញពីបញ្ហាធំៗជាច្រើន។ វិធីដោះស្រាយបញ្ហាទាំងនេះត្រូវធ្វើឲ្យប្រាកដប្រជាថា គ្រប់សេចក្តីសម្រេចរបស់តុលាការ ត្រូវផ្អែកលើភស្តុតាងជាសារវ័ន្ត និងសំអាងហេតុផ្លូវច្បាប់ ដែលចៅក្រមជាអ្នកសម្រេចមិនត្រូវមានចំណងពាក់ព័ន្ធផលប្រយោជន៍ផ្ទាល់ខ្លួន ហិរញ្ញវត្ថុ និងផលប្រយោជន៍ផ្សេងៗទៀតពីស្ថាប័ននីតិប្រតិបត្តិ និងបក្សនយោបាយណាមួយ។

## យន្តការដោះស្រាយទំនាស់ដីធ្លី

កង្វះដំណោះស្រាយប្រសិទ្ធភាពពីប្រព័ន្ធយុត្តិធម៌ ធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់អ្នកក្រីក្របំផុត អ្នកត្រូវគេដកហូតដីធ្លី និងអ្នកត្រូវគេផាត់ចេញ ព្រមទាំងអ្នកដែលស្ថិតក្នុងក្រុមប្រជាពលរដ្ឋភាគតិច និងក្រុមជនជាតិដើមភាគតិចនៅក្នុងប្រទេស និងផលប៉ះពាល់មានភាពធ្ងន់ធ្ងរបំផុតចំពោះអ្នកទាំងឡាយណាដែលត្រូវបានបណ្តេញចេញពីផ្ទះសម្បែងនិងដីធ្លី។ ដោយហេតុផលប្រវត្តិសាស្ត្រ និងហេតុផលដទៃទៀត បញ្ហាពាក់ព័ន្ធនឹងសិទ្ធិដីធ្លី គឺជាបញ្ហាសិទ្ធិមនុស្សចម្បង និងបន្តនៅតែជាបញ្ហាសិទ្ធិមនុស្សចម្បងគេក្នុងប្រទេស។ នៅពេលដែលខ្ញុំចាប់ផ្តើម បំពេញតួនាទីរបស់ខ្ញុំ ខ្ញុំមានកង្វល់អំពីផលប៉ះពាល់នៃដីសម្បទានសេដ្ឋកិច្ចលើសិទ្ធិមនុស្ស។ ខ្ញុំមានសេចក្តីរីករាយដោយនៅក្នុងសប្តាហ៍នៃបេសកកម្មរបស់ខ្ញុំក្នុងខែឧសភា ឆ្នាំ២០១២ ដែលពេលនោះផ្តោតលើដីសម្បទានសេដ្ឋកិច្ច រដ្ឋាភិបាលបានចេញនូវបទបញ្ជាថ្មីមួយដាក់ឲ្យមានការផ្អាកជាបណ្តោះអាសន្នការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មី និងសន្យាធ្វើការត្រួតពិនិត្យឡើងវិញលើដីសម្បទានដែលមានស្រាប់ ដែលវិធានការទាំងពីរនេះក៏ជាអនុសាសន៍ដែលខ្ញុំបានផ្តល់ផងដែរ។ កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យស្របច្បាប់នូវសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋក្រីក្រតាមតំបន់ជនបទ តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិតាមបទបញ្ជា ០០១ គឺជាការគួរកោតសរសើរ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលជាការពិតនោះគឺថា កិច្ចខិតខំទាំងនេះ នៅបន្តផាត់ចេញតំបន់ប្រទាញប្រទង់ដែលទំនាស់ដីធ្លីមានភាពស្រួចស្រាល់។ មានសេចក្តីរាយការណ៍ថា តួលេខនៃទំនាស់ដីធ្លី និងចំនួនគ្រួសារដែលប៉ះពាល់ពីទំនាស់ទាំងនេះមានការកើនឡើងខ្លាំងក្នុងឆ្នាំ២០១៤។ ទំនាស់ដីធ្លីដែលមានភាពរ៉ាំរ៉ៃក្នុងចំនួនដ៏ច្រើននៅតែមិនទាន់ត្រូវបានដោះស្រាយនៅឡើយដែលករណីខ្លះទំនាស់មានរយៈពេលមួយទសវត្សកន្លងមកហើយ។

ខ្ញុំទទួលបានញត្តិដ៏ច្រើនលើសលុបពីសហគមន៍នានា ក្នុងអំឡុងទស្សនកិច្ចរបស់ខ្ញុំ ក្នុងសប្តាហ៍នេះ និងក្នុងទស្សនកិច្ចលើកមុនៗ ដែលសហគមន៍ទាំងអស់នោះធ្លាប់បានដាក់បណ្តឹងរបស់ពួកគេទៅស្ថាប័នតុលាការ គណកម្មការសុរិយោដី គណកម្មការសិទ្ធិមនុស្សរបស់រដ្ឋសភា និង គណ

កម្មការជាតិដោះស្រាយទំនាស់ដីធ្លី ហើយដែលពួកគេត្រូវបានបដិសេធនូវការទទួលបានយុត្តិធម៌ជាបន្តបន្ទាប់។ សហគមន៍ទាំងនោះមានទាំងសហគមន៍ជនជាតិដើមភាគតិចមកពីបណ្តាខេត្តនានាជុំវិញប្រទេសផង ហើយដែលពួកគេភាគច្រើនមករកខ្ញុំនៅរៀងរាល់បេសកកម្ម របស់ខ្ញុំដើម្បីសុំឲ្យជួយដល់ពួកគេ។ ការខ្វះភាពប្រសើរឡើងនៃការការពារសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចពូនង ក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគីរី ជាឧទាហរណ៍ និងការមិនអើពើចំពោះការច្បាមយកដីធ្លីក្នុងតំបន់ដែលធ្លាប់កាន់កាប់រស់នៅដោយសហគមន៍ទាំងនេះ និងសហគមន៍ដទៃៗទៀតបានគំរាមកំហែងធ្វើឲ្យសាបសូន្យដល់វប្បធម៌ជនជាតិដើមភាគតិចទាំងស្រុង។

ការទាញយកអត្ថប្រយោជន៍ពីធនធានធម្មជាតិរបស់ប្រទេស ពីដីមានជីជាតិ ព្រៃឈើ និងទន្លេ ហាក់ដូចជាផ្តល់ផលប្រយោជន៍ដល់តែមនុស្សមួយចំនួនតូចប៉ុណ្ណោះ ហើយភាគច្រើនមិនបានទទួលផលនេះទេ។ ក្រុមហ៊ុនឯកជនបានឈូសឆាយដីដែលមានទំនាស់ ដុតផ្ទះ និង ពាក់ព័ន្ធក្នុងសកម្មភាពកាប់ឈើខុសច្បាប់ ដោយទទួលបានការការពាររួចផុតពីការផ្តន្ទាទោស។ ប្រជាពលរដ្ឋទាំងឡាយណាដែលក្លាហានហ៊ានងើបឈរឡើងរាយការណ៍ពីបញ្ហារំលោភបំពានទាំងនេះ ត្រូវបាននាំយកមកផ្តន្ទាទោសដោយតុលាការដែលជាស្ថាប័នគួរផ្តល់ការការពារដល់សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានរបស់ពួកគេ។

រដ្ឋាភិបាលត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីអនុវត្តការត្រួតពិនិត្យមើលឲ្យបានត្រឹមត្រូវលើសហគ្រាសពាណិជ្ជកម្មដែលអភិវឌ្ឍខាងដីធ្លី ឬក៏ផ្តល់ឲ្យមានសំណងជួសជុលការខូចខាតចំពោះអំពើអន្តរាយដែលបង្កឡើងដោយក្រុមហ៊ុនឯកជន។ កាលពីថ្ងៃពុធ ខ្ញុំបានទៅពិនិត្យមើលតំបន់បុរីកីឡាម្តងទៀត ដែលអ្នករស់នៅទីនោះបន្តរស់នៅក្នុងស្ថានភាពដែលមិនអាចទទួលយកបានទេសម្រាប់សតវត្សទី២១នេះ ហើយជាទីតាំងដែលស្ថិតក្នុងរាជធានីនៃប្រទេសមួយដែលបានអះអាងពីកំណើនសេដ្ឋកិច្ចដ៏ខ្លាំងរបស់ខ្លួនបែបនេះ។ នៅពេលជួបពិភាក្សាជាមួយតំណាងសភាពាណិជ្ជកម្មកម្ពុជា ក្នុងសប្តាហ៍នេះ ខ្ញុំបានលើកឡើងពីកង្វល់នានារបស់ខ្ញុំ និងបានសង្កត់ធ្ងន់លើការពិតដែលថា ខ្លួនខ្ញុំផ្ទាល់ និងខ្ញុំជឿជាក់ថាប្រជាពលរដ្ឋកម្ពុជាទាំងអស់ ទទួលស្គាល់អំពីតម្រូវការនៃការមានថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់តាមផ្ទះ និងតាមសហគ្រាសនានា។ ខ្ញុំមានសេចក្តីរីករាយដែលយើងបានព្រមព្រៀងគ្នាជាស្រេចថា សេចក្តីត្រូវការនេះគួរតែអាចឆ្លើយតបបានតាមរយៈដំណើរការពិគ្រោះយោបល់ត្រឹមត្រូវប្រកបដោយការចូលរួម ដោយមានសំណងសមរម្យ និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត។ បទដ្ឋានអំពីការព្រមព្រៀង ដោយសេរី និងការផ្តល់ដំណឹងជាមុន

ត្រូវតែអនុវត្តឲ្យបានហ្មត់ចត់នៅពេលពិគ្រោះយោបល់ជាមួយសហគមន៍ និងសហគមន៍ជនជាតិដើមភាគតិច ដែលរួមមានទាំងចំពោះគម្រោងនានាដែលវាមានសារៈសំខាន់សម្រាប់ប្រទេសជាតិ ដូចជា គម្រោងសាងសង់ទំនប់វារី អគ្គីសនីជាដើម។ គ្មាននរណាម្នាក់ត្រូវបានរុញច្រានឲ្យធ្លាក់ក្នុងស្ថានភាពក្រីក្របំផុត ដោយសារតែសេចក្តីត្រូវការថាមពលអគ្គីសនីនោះទេ។

ខ្ញុំព្រួយបារម្ភណ៍ថា ការគ្រប់គ្រង និងដំណើរការនៃការត្រួតពិនិត្យឡើងវិញដែលកំពុងតែប្រព្រឹត្តទៅលើដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានដទៃទៀត នៅបន្តញាំញីទៅដោយការខ្វះតម្លាភាព គណនីយភាព ការតាមដានមើលដោយឯករាជ្យ ឬការពិនិត្យតាមដានពីសាធារណៈជន។ ការដណ្តើមយកដីធ្លី និងកង្វះដំណោះស្រាយផ្លូវច្បាប់សម្រាប់ជនរងគ្រោះពីការរំលោភបំពានទាំងនេះ បន្តធ្វើឲ្យអន្តរាយដល់ការអភិវឌ្ឍនៅកម្ពុជា។ ខ្ញុំជឿថា បញ្ហានេះដែលខ្លាំងជាងបញ្ហាផ្សេងៗទៀត បានធ្វើឲ្យសាធារណជនបាត់បង់ការជឿជាក់ និងទំនុកចិត្ត ទាំងលើប្រព័ន្ធតុលាការ និងលើរដ្ឋាភិបាលទាំងមូល។ ទំនាស់ដីធ្លីនឹងបន្តមានយូរតទៅទៀត លុះត្រាតែស្ថាប័នឯករាជ្យ មានសមត្ថភាព និងជឿទុកចិត្តបាន ទាំងជាតុលាការក្តី ឬអជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានការកែទម្រង់ក្តី អាចដោះស្រាយបណ្តឹងនានាប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធិភាព។

## គណកម្មការឯករាជ្យរបស់នគរបាលជាតិទទួលពាក្យបណ្តឹង

ដោយមានទំនុកចិត្តកំរិតទាបពេកទៅលើប្រព័ន្ធយុត្តិធម៌ពីសំណាក់មហាជន ក៏ដូចជាស្ថាប័នរដ្ឋដ៏ទៃទៀតដូចបានរៀបរាប់ខាងលើ តាមទស្សនខ្ញុំ គឺថាស្ថាប័នឯករាជ្យមួយចំនួន ដែលមានអាណត្តិការងារជាក់លាក់ អាចនឹងជួយបំពេញនូវភាពខ្វះចន្លោះនេះ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ប្រទេសកម្ពុជា ដែលស្ថាប័នរដ្ឋកម្ពុជាជាច្រើនមានអំណាចយុត្តិធម៌ ឬអំណាចពាក់កណ្តាលយុត្តិធម៌ ដើម្បីចាប់ខ្លួនប្រជាពលរដ្ឋ ហើយដែលភស្តុតាងជាច្រើនត្រូវបានទាត់ចោលយ៉ាងងាយដោយតុលាការ ការមានយន្តការត្រួតពិនិត្យបែបនេះមានតម្លៃបំផុតដែលអាចបង្ការនូវការរំលោភអំណាច ហើយវានឹងមានប្រសិទ្ធិភាព និងបង្កើនជំនឿទុកចិត្តពីមហាជន ល្ហឹកណាតែមានឯករាជ្យពេញលេញពីអំណាចដែលមានតួនាទីត្រួតពិនិត្យ។

ដោយសារកង្វះការស៊ើបអង្កេតលើសកម្មភាពរបស់នគរបាលដែលបានរំលោភ ទៅលើបទដ្ឋាននានា រួមទាំងការបាញ់ប្រហារកាលពីឆ្នាំមុន និងករណីរំលោភបំពានផ្សេងៗទៀតដែលខ្ញុំបានទទួល វាស្តែងឲ្យឃើញថាការបង្កើតនូវស្ថាប័ននគរបាលជាតិឯករាជ្យគឺពិតជាចាំបាច់ណាស់។

ក្នុងករណី ដែលយន្តការទទួលខុសត្រូវជាប្រពៃណីគ្មានប្រសិទ្ធិភាព ការចូលរួមត្រួតពិនិត្យរបស់មហាជនពីខាងក្រៅអាចជួយបំពេញភាពខ្វះចន្លោះទាំងនេះ។ នៅក្នុងប្រទេសមួយចំនួនការចូលរួមត្រួតពិនិត្យរបស់មហាជនគឺធ្វើតាមរយៈស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ។ ចំពោះប្រទេសដទៃទៀត យន្តការទទួលខុសត្រូវ មានទម្រង់ជាស្ថាប័ននគរបាលជាតិឯករាជ្យ។ អង្គភាពនេះអាចទទួលពាក្យបណ្តឹងពីការរំលោភបំពានរបស់នគរបាល ស៊ើបអង្កេតពាក្យបណ្តឹងទាំងនេះ រួចកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នតុលាការ ក្នុងករណីចាំបាច់ត្រូវដាក់វិធានការណ៍វិន័យ ហើយលើកសំណើរសុំឲ្យមានការកែទម្រង់សេវាកម្មនគរបាល។

ការបង្កើតស្ថាប័នបែបនេះជួយកែលំអរទំនាក់ទំនងរវាងកំលាំងនគរបាលនិងសាធារណជន ហើយបង្កើននូវទំនុកចិត្តពីប្រជាពលរដ្ឋមកលើស្ថាប័ននគរបាល។

## អង្គភាពប្រឆាំងអំពើពុករលួយ

ស្ថាប័នមួយក្នុងចំណោមស្ថាប័នថ្មីដ៏សំខាន់បំផុតដែលត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជា គឺអង្គភាពប្រឆាំងអំពើពុករលួយ (ACU)។ ការបង្កើតស្ថាប័ននេះ ត្រូវបានអនុវត្តតាមការផ្តួចផ្តើមសំខាន់ៗជាច្រើន ដូចជា ការខិតខំប្រឹងប្រែងដើម្បីលុបបំបាត់មន្ត្រីរាជការ "ខ្មោច" ពីបញ្ជីប្រាក់បៀវត្សនិងការចំណាយទៅលើប្រាក់ខែមន្ត្រីរាជការតាមរយៈការផ្ទេរគណីតាមធនាគារ ដែលខ្ញុំជឿជាក់ថានឹងនាំមកនូវផលប្រយោជន៍យ៉ាងច្រើន ប្រសិនបើត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការផ្ទេរថវិកា នៅតែជាការលំបាកក្នុងការតាមដាន។ អំពើពុករលួយដែលរីករាលដាល ត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អ ហើយទោះបីជាមានច្បាប់ប្រឆាំងអំពើពុករលួយក៏ដោយ ក៏វានៅតែជាឧបសគ្គដ៏ធំបំផុតក្នុងការសម្រេចបាននូវការរីកចំរើនតាមបែបចូលរួម ដែលប្រជាជនកម្ពុជាទាមទារឲ្យមាន។

តាមរយៈបទពិសោធន៍ពីប្រទេសជាច្រើន ដែលធ្វើការកាត់បន្ថយអំពើពុករលួយប្រកបដោយជោគជ័យ ឯករាជ្យភាព គឺជាកត្តាដ៏សំខាន់សំរាប់ស្ថាប័នប្រឆាំងអំពើពុករលួយទាំងឡាយដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព។ អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដែលប្រទេសកម្ពុជាជាភាគី តម្រូវឲ្យរដ្ឋនានាបង្កើតឲ្យមានស្ថាប័នប្រឆាំងអំពើពុករលួយមួយដែលចាំបាច់ត្រូវតែមានឯករាជ្យភាព ក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ ដោយមិនត្រូវនៅក្រោមឥទ្ធិពលអ្នកនយោបាយ ឬអាជ្ញាធរផ្សេងៗទៀតឡើយ។ ខ្ញុំមានការសោកស្តាយ

ក្នុងការនិយាយថា ស្ថាប័នប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាលកម្ពុជា មិនបានបំពេញកាតព្វកិច្ចតាមតម្រូវការនេះឡើយ។ ស្ថាប័នេះ នឹងគេចផុតពីការចោទប្រកាន់ផ្សេងៗអំពីភាពលំអៀង និងក្រោមឥទ្ធិពលនយោបាល ប្រសិនបើ វិធានការផ្សេងៗ ត្រូវបានធ្វើឡើងដើម្បីកែតម្រូវឋានៈស្ថាប័ននេះ។

## យន្តការបង្ការទារុណកម្មថ្នាក់ជាតិ

កម្ពុជាគឺជាប្រទេសឈានមុខក្នុងតំបន់ដែលបានសំរេចផ្តល់សច្ចាប័នទៅលើពិធីសាបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម កាលពីឆ្នាំ ២០០៧។ ពិធីសាបន្ថែមនេះតម្រូវឲ្យរដ្ឋភាគីបង្កើតយន្តការបង្ការថ្នាក់ជាតិ (NPM)។ យន្តការបង្ការទារុណកម្មថ្នាក់ជាតិឯករាជ្យត្រូវធ្វើទស្សនៈកិច្ចទៅគ្រប់ទីកន្លែងឃាត់/ឃុំខ្លួនជាទៀងទាត់ រាប់ទាំងអង្គភាពឃាត់ខ្លួនរបស់នគរបាល ជាទីដែលមានបណ្តឹងអំពីការប្រព្រឹត្តមិនគប្បីមកលើខ្លួនដែលតែងតែកើតឡើងជាញឹកញាប់។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការអន្តរក្រសួងបង្ការទារុណកម្មថ្នាក់ជាតិដែលហៅដោយខ្លួនឯងថា (NPM)។ ខ្ញុំគូសបញ្ជាក់យ៉ាងម៉ឺងម៉ាត់ថា ជនរងគ្រោះដោយអំពើទារុណកម្ម មិនអាចរំពឹងទុកដោយពេញចិត្តក្នុងការទទួលបានយុត្តិធម៌ពីស្ថាប័ននេះដែលបណ្តោយឲ្យជនរងគ្រោះទទួលរងទារុណកម្មតាំងពីដើមដំបូង។ ខ្ញុំលើកទឹកចិត្តរាជរដ្ឋាភិបាលឲ្យបំពេញកាតព្វកិច្ចផ្លូវច្បាប់ដែលខ្លួនទទួលយកដោយស្ម័គ្រចិត្តដើម្បីបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិឯករាជ្យមួយ ហើយស្នើសុំជំនួយបច្ចេកទេសពីអនុគណៈកម្មការបង្ការទារុណកម្មអន្តរជាតិ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិក្នុងការបំពេញកាតព្វកិច្ចបែបនេះ។

## ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ

ស្ថាប័នជាតិឯករាជ្យដែលស្របតាមគោលការណ៍ទីក្រុងប៉ារីស ដែលត្រូវឃ្លាំមើល និងផ្តល់យោបល់អំពី វិស័យសិទ្ធិមនុស្សដល់រាជរដ្ឋាភិបាល និងត្រូវផ្តល់អំណាចឲ្យស៊ើបអង្កេតពីបណ្តឹងឯកត្តបុគ្គល បាន បង្ហាញថាជាយន្តការការពារសិទ្ធិមនុស្សមួយប្រកបដោយប្រសិទ្ធភាពនៅក្នុងបណ្តាប្រទេសជាច្រើន។ ដោយសារតែការខកខានរហូតមកដល់ពេលនេះ របស់សភាដើម្បីតំណាងឲ្យប្រជាពលរដ្ឋរបស់ខ្លួន ដ៏ មានប្រសិទ្ធភាព និងប្រព័ន្ធយុត្តិធម៌ក្នុងការផ្តល់យុត្តិធម៌ ការនេះកាន់តែប្រាកដថា ត្រូវតែមានយន្តការ បែបនេះមួយ ដោយរួមទាំងដើម្បីការពារសិទ្ធិស្ត្រី សិទ្ធិជនពិការ និងក្រុមងាយរងគ្រោះដទៃផ្សេងទៀត។

អភិក្រមរបស់រដ្ឋាភិបាលចង់ឲ្យបង្កើតស្ថាប័នរដ្ឋាភិបាលមួយជាជាងស្ថាប័នឯករាជ្យ។ គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជាដែលចំណុះឲ្យទីស្ដីការគណៈរដ្ឋមន្ត្រី គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នទាំងនោះ។ ទៅតាមការចាំបាច់ និងតាមសារប្រយោជន៍ដែលស្ថាប័នទាំងនេះត្រូវមាន ស្ថាប័នទាំងនេះមិនត្រូវទទួល បានជាស្ថាប័នឯករាជ្យតាមការជាក់ស្ដែងនោះទេ ដោយសារតែស្ថាប័នទាំងនេះមិនអាចបំពេញមុខងារ ប្រព័ន្ធត្រួតពិនិត្យតុល្យភាពដ៏សំខាន់នោះទេ។

អាស្រ័យហេតុនេះ ខ្ញុំមានក្ដីរំភើបដោយជ្រាបតាមរយៈដំណើរបេសកកម្មលើកនេះថា កិច្ចខិតខំប្រឹង ប្រែងធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សត្រូវបានធ្វើបន្តទៅមុខទៀត។ ទន្ទឹមនឹង ខ្ញុំមិនប្រញាប់ប្រញាល់ស្វាគមន៍ដ៏ឆាប់ពេកពីគំនិតផ្ដួចផ្ដើមនេះទេ ខ្ញុំសូមលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធ ទាំងអស់ ឲ្យធ្វើការជាមួយគ្នាដោយសហការគ្នា ដើម្បីផលប្រយោជន៍ល្អរបស់ប្រទេសជាតិ។ មានបញ្ហា ជាច្រើន ដូចជា ការស្អប់ជនបរទេស និងការរើសអើងពូជសាសន៍ សិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា និងសិទ្ធិជនពិការ ដែលមិនទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ពីស្ថាប័នរដ្ឋដែលមានស្រាប់ នោះ នឹងជាប្រយោជន៍ពីការឃ្លាំមើល និងអនុសាសន៍ជាគោលនយោបាលជាបន្តបន្ទាប់ ពីស្ថាប័នសិទ្ធិមនុស្ស ជាតិមួយដែលឯករាជ្យ។

## សេចក្ដីសន្និដ្ឋាន

រយៈពេល៦ឆ្នាំមុនបានកន្លងផុតទៅយ៉ាងឆាប់រហ័ស ដែលធ្វើឲ្យខ្ញុំក្លាយជាអ្នករាយការណ៍ពិសេសដែលបំរើការងារក្នុងរយៈពេលដ៏យូរជាងគេសម្រាប់ប្រទេសកម្ពុជា។ ដោយផ្ដល់ឲ្យខ្ញុំនូវគតិបណ្ឌិតទាំងក្ដីសោមនស្សរីករាយផ្ទាល់ខ្លួន និងខាងវិជ្ជាជីវៈ។ កម្មវិធីកែទម្រង់កំពុងត្រូវបានដោះស្រាយ ព្រមទាំងគណបក្សមានសម្លេងភាគច្រើន និងភាគតិច បានធ្វើការប្ដេជ្ញាចិត្តជាសាធារណៈ ដើម្បីអនុវត្តកំណែទម្រង់ការបោះឆ្នោត។ វាដល់ពេលវេលាដែលត្រូវពិនិត្យមើលនូវប្រព័ន្ធអភិបាលកិច្ចទាំងមូលឲ្យបានកាន់តែទូលំទូលាយហើយ។ ជារឿយៗ គេត្រូវចំណាយពេលវេលាយូរអង្វែង ដើម្បីអនុវត្តសេចក្ដីសម្រេច និងកំណែទម្រង់ទាំងមូល។ ខ្ញុំសង្ឃឹមថា ដំណាក់កាលនេះនឹងមិនមានការឆ្លើយដោះសារទៀតឡើយ ដើម្បីពន្យាការអនុវត្តកំណែទម្រង់នយោបាយដែលបានព្រមព្រៀងគ្នាជាកញ្ចប់ និងមិនងាកចេញពីវឌ្ឍនភាពនៃកិច្ចសន្ទនាគ្នាទេ ដែលបច្ចុប្បន្នកំពុងដំណើរការនៅក្នុងប្រទេស។

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានក្ដីសង្ឃឹម។ ផ្ដើមចេញពីកិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ប្រទេសនេះសម្រេចបាននូវការពុះពារយ៉ាងធំធេង ជារួមមាន ការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលទ្រទ្រង់ដោយស្ថេរភាពនយោបាយ។ ខណៈដែលប្រទេសនេះ ចាប់ផ្ដើមពន្លឿនកំណើនសេដ្ឋកិច្ច ការណ៍នេះបាននាំមកនូវបញ្ហាប្រឈមជាច្រើនអំពី ការអភិវឌ្ឍន៍ដោយអសមធម៌ ព្រមទាំងធ្វើឲ្យគំលាតរវាងអ្នកក្រ និងអ្នកមានកាន់រីកធំឡើង។ កាលពីពេលថ្មីៗនេះ មានការវិវត្តន៍ខាងនយោបាយ គួរឲ្យកត់សំគាល់កើតមានឡើង ដែលការវិវត្តន៍បែបនេះ ខ្ញុំជឿជាក់ថា នឹងមិនដើរថយក្រោយឡើយ។ វឌ្ឍនភាពសម្រេចបានកាលពីពេលថ្មីៗនេះ ហាក់ដូចជាបង្កើតឲ្យមានក្ដីសង្ឃឹម និងទំនុកចិត្តសម្រាប់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់យុវជនកម្ពុជា ដែលជាប្រយោជន៍នៃអនាគតប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ ភាពខុសគ្នាគួរឲ្យកត់សំគាល់រវាង ពីអតីតកាល និងបច្ចុប្បន្នកាលគឺ អាស្រ័យលើប្រជាពលរដ្ឋខ្លួនឯង។ ពួកគេនឹងមិនខ្លាចរអាក្នុងការសំដែងមតិទៀតឡើយ។ ប្រជាពលរដ្ឋយល់ដឹងអំពីសិទ្ធិរបស់គេ ព្រមទាំងត្រៀមខ្លួនក្នុងការទាមទារសិទ្ធិទាំងនោះ។ គ្មានអ្វីដែលសំដែងចេញប្រសើរជាងប្រជាធិបតេយ្យដ៏ចាស់ទុំរបស់កម្ពុជាឡើយ។ ខណៈដែលនៅតែមានវិធីជាច្រើន ដែលត្រូវធ្វើដំណើរឆ្ពោះទៅមុខនៅក្នុងការសម្រេចបាននូវចក្ខុវិស័យនៃប្រជាធិបតេយ្យសេរីពហុបក្ស និងទិសដៅបានដាក់ចេញក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនាឆ្នាំ១៩៩១ ដែលប្រាប់ឲ្យដឹងអំពីការលេចឡើងនៃប្រធិបតេយ្យថ្មីសម្រាប់ប្រទេសកម្ពុជា។ ខ្ញុំសូមធ្វើសេចក្ដីសន្និដ្ឋានអំពីបេសសកម្មចុងក្រោយរបស់ខ្ញុំ ដោយជឿជាក់យ៉ាងមុតមាំថា ប្រទេសកម្ពុជានឹងដើរឆ្ពោះដល់ទិសដៅនោះជាមិនខាន ដើម្បីធានារឿងនេះ ប្រជាពលរដ្ឋកម្ពុជាដ៏សកម្ម គឺជាអ្នកធានាថាវានឹងកើតឡើង។

ខ្ញុំមានកិត្តិយស និងបុព្វសិទ្ធិ ដែលមានលទ្ធភាពក្នុងការរួមវិភាគទាន ចំពោះការពង្រឹងនីតិរដ្ឋ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅប្រទេសកម្ពុជាក្នុងបរិបទប្រវត្តិសាស្ត្រដ៏សំខាន់នេះ ជាមួយនឹង ការធានាថា ខ្ញុំនឹងនៅតែជាមិត្តរបស់ប្រទេសកម្ពុជាជារៀងរហូត។ ខ្ញុំសូមជូនពរប្រជាពលរដ្ឋកម្ពុជា ទទួលបាននូវសំណាងល្អ ក្នុងការសម្រេចបានទិសដៅទាំងនេះ និងក្នុងការកសាងសង្គមមួយ ប្រកបដោយវិបុលភាព សមភាព និងសង្គមដែលមានយុត្តិធម៌ ជាអង្វែងតទៅ។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជា អ្នករាយការណ៍ ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ បច្ចុប្បន្ន*

*លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ និងជាមេធាវីអាជីពមួយរូប នៅចក្រភពអង់គ្លេស។ លោកសាស្ត្រាចារ្យ ស៊ូប៊ែឌី ក៏ជាអ្នក និពន្ធរបស់ទស្សនាវដ្ដីអាស៊ីផ្នែកនីតិអន្តរជាតិផងដែរ (បោះពុម្ពផ្សាយដោយការិយាល័យព័ត៌មាន នៃសាកលវិទ្យាល័យខេម ប្រីដជ៍ និងជាអនុប្រធាននៃសង្គមអាស៊ីផ្នែកនីតិអន្តរជាតិ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖*
http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx

*អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយដែលមានអ្នកជំនាញការឯករាជ្យច្រើនរូប ក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើលនិងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

*សំរាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក៖*
***នៅរាជធានីភ្នំពេញ៖*** *កញ្ញា ប៊ូស្រា រ៉ាម៉ាន់ តាមរយៈទូរស័ព្ទលេខ (+៨៥៥ ១២ ៧៩០ ១៧៨/* brahman@ohchr.org*)*
***នៅទីក្រុងហ្សឺណែវ៖*** *កញ្ញា* Olga Nakajo *តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល* onakajo@ohchr.org*) ឬសរសេរមកកាន់* srcambodia@ohchr.org

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមក ឈ្មោះ Xabier Celaya សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្ដាញព័ត៌មានសង្គម ៖**

ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights
ទ្វីតធើ៖ http://twitter.com/UNrightswire
ហ្គោហ្គីល៖ Google+ gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR
បរិយាយសាច់រឿង៖ http://storify.com/UNrightswire

ឆែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖ http://uhri.ohchr.org/en